



ចេញផ្សាយ ២៥ តុលា ២០២១

## ឯកឧត្តមរដ្ឋមន្ត្រី វេង សាខុន អមដំណើរដោយ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាប្រធានរដ្ឋបាលជលផល និងមន្ត្រីជំនាញបាន អញ្ជើញមកពិនិត្យកសិដ្ឋានចិញ្ចឹមត្រី របស់លោក ផៃ ជាត និងសិប្បកម្មកែច្នៃត្រីងៀតរបស់បងស្រី ធឿន ស្រីនី ដែលមានទីតាំងស្ថិតនៅក្នុងភូមិថ្មី ឃុំសូទិព្វ ស្រុកជើងព្រៃ ខេត្តកំពង់ចាម

នៅព្រឹកថ្ងៃសៅរ៍ ២ រោច ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥ ត្រូវនឹងថ្ងៃទី ២៣ ខែតុលា ឆ្នាំ២០២១ ដើម្បីជាការលើកទឹកចិត្ត ជំរុញ និងគាំទ្រដល់វារីវប្បករ ក្នុងស្រុកជើងព្រៃឲ្យកាន់តែរីកចម្រើនបន្ថែមទៀតទាំង ការងារបច្ចេកទេសចិញ្ចឹម ការបង្កាត់ពូជត្រី ការផលិតចំណី និងការកែច្នៃ ធ្វើយ៉ាងឲ្យបានសមស្របទៅតាមតម្រូវការទីផ្សារទាំងគុណភាព សុវត្ថិភាព និងតម្លៃ និងជាពិសេសស្របតាមបរិបទ





នៃស្ថានភាពរីករាលដាលជំងឺឆ្លងកូវីដ-១៩ ឯកឧត្តមរដ្ឋមន្ត្រី វេង សាខុន អមដំណើរដោយឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាប្រធានរដ្ឋបាលជលផល និងមន្ត្រីជំនាញបានអញ្ជើញមកពិនិត្យកសិដ្ឋានចិញ្ចឹមត្រីរបស់លោក ផៃ ផាត នៅភូមិបឹងជ្រោយ ឃុំសូទិព្វ ស្រុកជើងព្រៃ ខេត្តកំពង់ចាម។ កសិករ ផៃ ផាត និងសមាជិកក្រុមគ្រួសារមួយចំនួនទៀតចាប់ផ្តើមចិញ្ចឹមត្រីតាំងពីឆ្នាំ ២០០៨ ប្រភេទត្រីដែលគាត់ចិញ្ចឹមរួមមានត្រីឆ្ដោ និងត្រីប្រា លើផ្ទៃដី ៧០០០ម៉ែត្រក្រឡា ចែកចេញជា ៥ស្រះ (សរុប ៣០០០ ម៉ែត្រក្រឡា) មានសមត្ថភាពផលិតត្រីឆ្ដោ និងត្រីប្រាបាន ២៥-៣០ តោន/ឆ្នាំ ដោយប្រើចំណីផលិតខ្លួនឯង និងក្រុមហ៊ុន។ ម្ចាស់កសិដ្ឋានបានឲ្យដឹងថា







ដោយសារតម្រូវការទីផ្សារមានការកើនឡើងជាលំដាប់ កសិដ្ឋាន នឹងពង្រីកផ្ទៃដីចិញ្ចឹមបន្ថែមទៀត។

ចេញពីកសិដ្ឋាន លោក ផៃ ផាន ឯកឧត្តមរដ្ឋមន្ត្រី និងសហការីបានបន្តដំណើរមកកសិដ្ឋានចិញ្ចឹម និងសិប្បកម្មកែច្នៃត្រីងៀត របស់បងស្រី ធឿន ស្រីនី ដែលមានទីតាំងស្ថិតនៅក្នុង ភូមិថ្មី ឃុំសូទិព្វ ស្រុកជើងព្រៃ ខេត្តកំពង់ចាម។ បងស្រី ស្រីនី (០៩៩ ៨៨៤៨៣៨) បានជម្រាបថា៖ កសិដ្ឋាន បានដំណើរការមក ៧ឆ្នាំមកហើយ បច្ចុប្បន្នមានស្រះចិញ្ចឹមត្រីប្រាធំៗចំនួន ៨ ស្រះ សរុបដាក់កូនត្រីចិញ្ចឹម ១លានកូន។ ដោយអនុវត្តតាមគោលការណ៍បច្ចេកទេសចិញ្ចឹមត្រីដូចជាការផ្តល់ចំណី ការសំអាតស្រះ ការគ្រប់គ្រងប្រើប្រាស់ និងសម្អាតទឹក។







ល។ រួមផ្សំជាមួយពូជល្អ
ចំណីមាន គុណភាពលក្ខ
ខណ្ឌចិញ្ចឹមអំណោយផល
និងការថែទាំ កសិដ្ឋានអាច
ប្រមូលផល ៧០០តោន/ឆ្នាំ
ហើយអនាគតគ្រោងចិញ្ចឹម
ឲ្យបាន ១ ០០០តោន/ឆ្នាំ
ឆ្លើយតបតាមសេចក្ដីត្រូវការ
ទីផ្សារក្នុងស្រុក។ ចំពោះ
ការងារសិប្បកម្មកែច្នៃត្រី
ងៀតនេះបានចាប់ផ្ដើមដំណើរ
ការជិត ១០ឆ្នាំមកហើយ
ដោយផ្ដើមចេញពីការប្រើ
ប្រាស់សម្ភារៈ និងឧបករណ៍
កែច្នៃជាលក្ខណៈគ្រួសារ ជា
បន្តបន្ទាប់អាជីវកម្មនេះមាន
ការរីកចម្រើន នោះ
ដោយសារមានកត្តាសំខាន់ៗ
ជាច្រើនមានជាអាទិ៍៖ ការ
ជួយឧបត្ថម្ភ គាំទ្រ និងលើក
ទឹកចិត្តពីឯកឧត្តមរដ្ឋមន្ត្រី
និងមានរដ្ឋបាលជលផលចុះ
មក ជួយសហការផ្ទាល់លើ
ការងារបច្ចេកទេស ព្រម
ជាមួយនឹងកិច្ចសហការ ជួយ







ឧបត្ថម្ភ និងគាំទ្រ ពី USDA, American Soybean Association, World Initiative for Soy in Human Health (WISHH), Commercialization of Aquaculture for Sustainable Trade Cambodia, World Vision និងសមាគមយុវជនក្រុម៨ ធ្វើឲ្យទំហំអាជីវកម្មកែច្នៃត្រីងៀតនេះ មានការរីកធំធាត់ ដូចយើងបានឃើញនាពេលនេះ។ ជាក់ស្តែង បច្ចុប្បន្នសិប្បកម្មបានកែច្នៃត្រីស្រស់ ត្រីរ៉ស់ ត្រីប្រា និងត្រីអណ្តែង បានជាង ៣០តោន/ខែ គិតជាត្រីងៀត (ហាលស្ងួត) បានចំនួន ១០តោន/ខែ ដោយត្រូវការថវិកាសម្រាប់ធ្វើការចំណាយលើការកែច្នៃត្រី ៣០តោន អស់ប្រមាណ ២៤០លានរៀល។ ក្នុងមួយខែបងស្រីអាចលក់ត្រីងៀតបាន ៣០០លានរៀល ផ្តត់







ផ្គង់ទៅកាន់ទីផ្សារ ដែលមាន៖ ផ្សារស្គន់ ភោជនីដ្ឋាននានាតាមរោងចក្រកាត់ដេរកាលីនតុន និងជូហ៊្វយនៅក្នុងស្រុកជើងព្រៃ និងផ្សារម្លប់បៃតងស្រស់នៅភ្នំពេញ។ល។ ក្រៅពីត្រីងៀត បងស្រីបានផ្គត់ផ្គង់ ត្រីស្រស់ចំនួន ២តោន/ថ្ងៃ ឲ្យទៅផ្សារស្គន់ផងដែរ។ ប្រភពត្រីស្រស់ដែលយកមកកែច្នៃ គឺបង ស្រីប្រមូលពីវារីវប្បករនៅទូទាំងស្រុកជើងព្រៃនេះតែម្តង។ពាក់ព័ន្ធការងារបច្ចេកទេសកែច្នៃសិប្បកម្មបានទទួលការឧបត្ថម្ភ និងគាំទ្របច្ចេកទេសពីរដ្ឋបាលជលផល និងគម្រោង CAST ក្នុងការលើកកម្ពស់ការអនុវត្តអនាម័យល្អ និងផលិតកម្មល្អ ដើម្បីឆ្លើយតបនឹងស្តង់ដារសុវត្ថិភាពចំណីអាហារ ជាងនេះទៅទៀតថ្មីៗនេះ រដ្ឋបាលជលផលបានប្រគល់នូវវិញ្ញាបនបត្របញ្ជាក់ពីការអនុវត្ត







អនាម័យល្អ និងផលិតកម្មល្អ (GHP & GMP) ចំពោះទីតាំងកែច្នៃត្រីងៀត និងវិញ្ញាបនបត្របញ្ជាក់ពីការធ្វើវារីវប្បកម្មល្អ (GAqP) ចំពោះកសិដ្ឋានវារីវប្បកម្ម។ ពិនិត្យឃើញទិដ្ឋភាពជារួមទាំងសកម្មភាពចិញ្ចឹមសកម្មភាព និងដំណើរការកែច្នៃត្រីងៀត ឯកឧត្តមរដ្ឋមន្ត្រីបានកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះការខិតខំប្រឹងប្រែងប្រកាន់យករបរចិញ្ចឹមត្រី និងសិប្បកម្មកែច្នៃត្រីងៀត ដើម្បីចូលរួមចំណែកបំពេញសេចក្តីត្រូវការទីផ្សារទាំងត្រីស្រស់ និងត្រីងៀតក្នុងស្រុក ប្រើប្រាស់វត្ថុធាតុដើម (ត្រីគ្រប់ប្រភេទ) បង្កើតការងារ និងបង្កើនតម្លៃបន្ថែម ដើម្បីកំណើនសេដ្ឋកិច្ចគ្រួសារ និងសេដ្ឋកិច្ចសហគមន៍ និងជាពិសេសដើម្បីចូលរួមកាត់បន្ថយបញ្ហាទីផ្សារចំពោះត្រីស្រស់ និង







កាត់បន្ថយការនាំចូល។ ឃើញច្បាស់ពីភាពជោគជ័យដែលបងស្រី និងសមាជិកសម្រេចបាននាពេលនេះ ឯកឧត្តមរដ្ឋមន្ត្រីបានលើកទឹកចិត្តឱ្យវារីវប្បកររៀបចំបណ្តុំចិញ្ចឹមត្រីដើម្បីផ្គត់ផ្គង់បរិមាណត្រីដល់សិប្បកម្មឲ្យបានគ្រប់គ្រាន់ ដើម្បីបន្តរក្សាមុខ របរចិញ្ចឹមត្រីនៅក្នុងស្រុកមាននិរន្តរភាព និងវឌ្ឍនភាព និងវិបុលភាពសេដ្ឋកិច្ច។ ឆ្លៀតយកឱកាសនេះ លោកបានណែនាំឱ្យរដ្ឋបាលជលផល និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត និងសមាគមវារីវប្បករកម្ពុជាជួយលើការងារបច្ចេកទេសចិញ្ចឹម និងកែច្នៃថ្មីៗបន្ថែម ទៀតដើម្បីរក្សានិរន្តរភាពផលិតកម្មចិញ្ចឹម ហើយគួរជួយរៀបចំផែនការផលិតកម្ម ចងក្រងបណ្តុំអ្នកចិញ្ចឹម និងបញ្ចូលបច្ចេកទេសទាក់ទងការគ្រប់គ្រង








ទឹកកខ្វក់ និងបរិស្ថានចិញ្ចឹម ឈានឆ្ពោះទៅបំពេញឲ្យ បានគ្រប់គ្រាន់ ត្រឹមត្រូវតាម ស្តង់ដារអន្តរជាតិដើម្បីឈាន ទៅធ្វើការនាំចេញនាពេល អនាគត។ រដ្ឋបាលជលផល ត្រូវសិក្សា និងពិនិត្យលទ្ធភាព បន្ថែមក្នុងការនាំយកសមា ជិកសហគមន៍វារីវប្បករនៅ ទូទាំងប្រទេសមកធ្វើទស្សន កិច្ចសិក្សាស្វែងយល់ និងដក ស្រង់បទពិសោធន៍ពីភាព ជោគជ័យរបស់បងស្រីធ្វើ នេះដើម្បីយើងទាំងអស់គ្នា ហើយយើងទាំងអស់គ្នាគឺ ដើម្បីវិស័យវារីវប្បកម្មកម្ពុជា រីកចម្រើននាពេលអនាគត។










